**ប្រកាសលេខ ០៥៤ ប្រក.សហវ**

**ស្តីពី**

**ការបង្កើតក្រុមការងារអចិន្ត្រៃយ៍សំរាប់**

**ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យនៃអង្គភាពគ្រប់គ្រងគំរោងការ «PMU»**

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញប្រកាសលេខ ២៨៩ ប្រ.ក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោងការ ហៅកាត់ « អគគ » (Project Management Unit ) ;
- បានឃើញការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : បង្កើតក្រុមការងារអចិន្ត្រៃយ៍សំរាប់ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ នៃអង្គភាពគ្រប់គ្រងគំរោងការ (PMU) ដែលមានសមាសភាពដូចតទៅ :

ក– អ្នកសំរបសំរួលការងារ ( Coordinator ) :

១.- លោកស្រី **អា ផៀសអាល់ម៉ែ**

ខ–អ្នកទទួលខុសត្រូវផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ : (Responsibility of Accounting and Finance ) :

១ - លោក **អ៊ុយ ឈើន** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ជាប្រធានគណនេយ្យ និង ហិរញ្ញវត្ថុផ្នែកទី១,

២ - លោក **ជាវ ចុំកច្ចូរ** អនុប្រធាននាយកដ្ឋានរបបគណនេយ្យជាប្រធានគណនេយ្យ និង ហិរញ្ញវត្ថុផ្នែកទី ២ ,

គ - ផ្នែករដ្ឋបាល :

១ - លោក **ជារី ចេតនា** មន្ត្រីរាជការនៅការិយាល័យសិក្សាស្រាវជ្រាវ និង សម្របសម្រួលរតនាគារជាតិ

ឃ - ប្រធានផ្នែក :

១ - លោក **រស់ បរម** មន្ត្រីអធិការកិច្ចនៅនាយកដ្ឋានអធិការកិច្ច ហិរញ្ញវត្ថុ ជាប្រធានផ្នែកទី ១ ,

២– លោក **យូ គិរម្យ** មន្ត្រីរាជការនៅនាយកដ្ឋានថវិកាជាប្រធានផ្នែកទី ២ ,

ង - មន្ត្រីរាជការនៅផ្នែកទី ១

១ - លោក **ខាត្រ ម៉ិនឥន្ទ្រាខុន** មន្ត្រីរាជការនៅការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ,

២ - លោក **ម៉ែន ឌីវុត្ថ** មន្ត្រីរាជការនៅការិយាល័យសហប្រតិបត្តិការអន្តរជាតិ នៃ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ,

៣ - លោក **គីម សុផល** មន្ត្រីរាជការនៅការិយាល័យពាណិជ្ជកម្ម នៃនាយកដ្ឋានហិរញ្ញកិច្ច ,

៤ - លោក **ខង់ ពេជ្រ** អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ ,

ច–មន្ត្រីរាជការនៅផ្នែកទី ២

១ - លោក **យ៉ិន សុគី** មន្ត្រីរាជការនៅអង្គភាពមន្ទីរ ,

២ - លោក **សេខ ម៉ុនលី** មន្ត្រីហិរញ្ញកិច្ច ,

៣- លោក **ជេត សំអឿន** មន្ត្រីអធិការកិច្ច ,

៤ - លោក **ឡាច ហ៊ិន** មន្ត្រីរាជការនៅការិយាល័យសិក្សាស្រាវជ្រាវ និង សម្របសម្រួលរតនាគារជាតិ ។

**ប្រការ ២** : ក្រុមការងារនេះ មានការិយាល័យបំពេញការងារស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣** : ក្រុមការងារនេះ ជាជំនួយការអោយអង្គភាពគ្រប់គ្រងគំរោងការ « PMU » ដើម្បីអនុវត្តនូវភារៈកិច្ចដូចតទៅ ÷

- តាមដាន និង ត្រួតពិនិត្យជាអចិន្ត្រៃយ៍លើការងារអនុវត្តន៍ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យ របស់បណ្តាក្រសួង ;
- ទទួលខុសត្រូវក្នុងការគ្រប់គ្រង Trust Fund ;
- ផ្សព្វផ្សាយ និង ជួយបំពាក់បំប៉នមុខជំនាញអោយដល់អង្គភាពរៀបចំគំរោង "PPU" របស់បណ្តាក្រសួងដែលត្រូវគ្រប់គ្រង World Bank Loan ;
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារអនុវត្ត ផ្នែកហិរញ្ញវត្ថុ និង គណនេយ្យក្នុងក្របខ័ណ្ឌ Trust Fund និង World Bank Loan របស់បណ្តាក្រសួង ។

**ប្រការ ៤** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានចំណុះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មន្ត្រីដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះ ។

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *